# អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍
# Action for Research and Development

សមត្ថភាព គុណភាព តម្លាភាព
Capacity Quality Transparency

ផ្ទះលេខ ៥១F ផ្លូវ ២៦៥ សង្កាត់ ទឹកល្អក់ ៣
ខណ្ឌទួលគោក ក្រុងភ្នំពេញ កម្ពុជា
ទូរសព្ទលេខ: ០១៦ ៧៧៨ ៧០១
អ៊ីម៉ែល: ard.cambodia@yahoo.com
ard.info@yahoo.com
ប្រអប់សំបុត្រ: CCC ៣០៤

# ព័ត៌មានសំខាន់សំរាប់អ្នក
# Necessary News for You

## ព្រឹត្តិបត្រព័ត៌មានប្រចាំខែ
## Monthly Newsletter

ចែកជូនដោយឥតគិតថ្លៃ

### មាតិកាព័ត៌មាន

- ការរីកចំរើនឯកសារនៅបណ្ណាល័យ ARD.................................. ២
- ជំណឹងជ្រើសរើសបុគ្គលិក.............................................. ៣
- ការយល់ដឹងបន្ថែមអំពី ប.វ.ស......................................... ៥
- បទពិសោធន៍កំចាត់ក្តាមកាត់ស្រូវដោយប្រើលាមកសេះ........................ ៦
- ប្រទេសកម្ពុជា បាន និងកំពុងទទួលរងនូវការគំរាម កំហែងដោយសារទំនប់..... ៧
- របាយការណ៍: អនាគតយុវជនកម្ពុជាមិនទាន់មានភាពច្បាស់លាស់................ ៨
- ម្តាយគ្រូបង្រៀនដែលជាប់ ពន្ធនាគារសុំទោសចំពោះ នាយករដ្ឋមន្ត្រី............ ៩
- សូមបោះឆ្នោតជូនប្រាសាទអង្គរវត្ត ជាអច្ឆរិយទាំង៧ក្នុងពិភពលោក............. ១០

**ពតិមានសំខាន់សំរាប់អ្នក** រៀបចំ និងបោះពុម្ពដោយអង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ (ARD)

# កម្មវិធីរបស់ ARD

## ការរីកចំរើនឯកសារនៅ បណ្ណាល័យអង្គការ ARD

អង្គការសកម្មភាពដើម្បី ស្រាវជ្រាវ និងអភិវឌ្ឍន៍ (អេ អ ឌី) បានដំណើរការ និងរៀបចំបណ្ណាល័យសំរាប់សិស្ស និស្សិត និងអ្នកសិក្សាស្រាវជ្រាវ គ្រប់មជ្ឈដ្ឋាន ចូលអាន និងខ្ចីសំរាប់ការអភិវឌ្ឍន៍ចំណេះដឹងរបស់ខ្លួន។ ចាប់តាំងពីការដំណើរការសកម្មភាពរបស់ខ្លួនមក អង្គការសកម្មភាពដើម្បីស្រាវជ្រាវ បានផ្តល់អាទិភាពសំខាន់ទៅលើការពង្រឹងសមត្ថភាពដល់ប្រជា-ពលរដ្ឋកម្ពុជា ជាពិសេសស្រទាប់និស្សិត និងបុគ្គលិកអង្គការ ស្ថាប័ននានា តាមរយៈការបង្កើតជាវគ្គបណ្តុះបណ្តាលខ្លីៗ ការចុះទស្សនៈកិច្ចសិក្សាតាមគំរោងអភិវឌ្ឍន៍នានា ការទទួលអោយនិស្សិតចូលមកធ្វើជាអ្នកស្ម័គ្រចិត្ត និងការបើកបណ្ណាល័យសំរាប់ការអាន ស្រាវជ្រាវ ជាដើម។

បណ្ណាល័យរបស់អង្គការអេ អ ឌី រួមមានផ្ទុកសៀវភៅសំរាប់អាន សិក្សា និងស្រាវជ្រាវទៅលើផ្នែកបច្ចេកទេសកសិកម្ម ជាលក្ខណៈគ្រួសារ ការងារអភិវឌ្ឍន៍សហគមន៍ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ការគ្រប់គ្រងទូទៅ ការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ យេនឌ័រ វិទ្យាសាស្ត្រកុំព្យូទ័រ និងអក្សរសាស្ត្រអង់គ្លេស។ សកម្មភាពទាំងនេះ គឺជាការឆ្លុះបញ្ចាំងអោយឃើញពីស្មារតីទទួលខុសត្រូវខ្ពស់ និងចូលរួមចំណែកយ៉ាងសកម្មនៅក្នុងការបង្កើនចំណេះដឹង សមត្ថភាពរបស់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសដល់និស្សិត ដែលជាអនាគតសសរទ្រូងសំរាប់អភិវឌ្ឍន៍ប្រទេសជាតិ។ ដើម្បីពង្រឹង និងពង្រីកនូវសេវាបណ្ណាល័យអោយកាន់តែមានប្រជាប្រិយភាពនៅក្នុងចំណោមអ្នកសិក្សា ស្រាវជ្រាវ អង្គការសកម្មភាពដើម្បីស្រាវជ្រាវ បាន និងកំពុងធ្វើការស្វែងរកជំនួយជាសៀវភៅ ឯកសារផ្សេងៗពីបណ្ដាអង្គការ ស្ថាប័ននានា ដែលអាចផ្តល់ជាជំនួយសំរាប់បណ្ណាល័យរបស់យើង។ នៅក្នុងចំណោមស្ថាប័ននានាជាង១០ ដែលអង្គការអេ អ ឌីបានធ្វើសំណើរ សុំឯកសារ ទស្សនាវដ្តី មានអង្គការ-ស្ថាប័នមួយចំនួន បានឆ្លើយតប និងផ្តល់ជំនួយទៅតាមសំណូមពររួចហើយសំរាប់បណ្ណាល័យ ដែលក្នុងនោះមាន អង្គការ Asia Foundation, PADEK, Oxfam UK, CEDAC, FACT, ADB, UNDP, CFI, ដែលតាមរយៈការផ្តល់ជំនួយបន្ថែមនេះ ធ្វើអោយបណ្ណាល័យអង្គការអេ អ ឌី នាពេលបច្ចុប្បន្ននេះមានឯកសារសំរាប់បំរើដល់និស្សិត បុគ្គលិកអង្គការ-ស្ថាប័ននានា ព្រមទាំងអ្នកសិក្សា ស្រាវជ្រាវទូទៅ សរុបជាង ៧០០ក្បាលហើយ។ អង្គការអេ អ ឌី សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះបណ្តាលអង្គការ-ស្ថាប័នដែលមានរៀបរាប់ខាងលើ នៅក្នុងការផ្តល់ជាជំនួយឯកសារសំរាប់ប្រើប្រាស់នៅក្នុងបណ្ណាល័យនេះ ហើយយើងក៏សង្ឃឹមជឿជាក់យ៉ាងមុតមាំផងដែរថា អង្គការ-ស្ថាប័នដែលមិនទាន់បានឆ្លើយតប និងផ្តល់ជាជំនួយនោះ នឹងពិចារណា និងឆ្លើយតបជាវិជ្ជមាន ក្នុងគោលដៅរួមចំណែកនៅក្នុងការអភិវឌ្ឍន៍ចំណេះដឹង និងសមត្ថភាពដល់ប្រជាពលរដ្ឋកម្ពុជា។

បណ្ណាល័យអង្គការអេ អ ឌី បើកបំរើសេវាជូនដល់សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវគ្រប់មជ្ឈដ្ឋានអោយចូលអាន រីខ្ចីឯកសារផ្សេងៗដោយឥតគិតថ្លៃ នៅរៀងរាល់ថ្ងៃធ្វើការ ចាប់ពីថ្ងៃច័ន្ទ ដល់សុក្រ ព្រឹកចាប់ពីម៉ោង ០៨:០០ ដល់ម៉ោង ១២:០០ និងពេលរសៀលពីម៉ោង១៤:០០ ដល់ម៉ោង១៧:០០។ បណ្ណាល័យ មានបញ្ជីសៀវភៅឯកសារដែលបែងចែក និងទុកដាក់ ទៅតាមផ្នែកផ្សេងៗមានភាពងាយស្រួលក្នុងការស្រាវជ្រាវរកតាមគោលបំណងរបស់អ្នកសិក្សា ស្រាវជ្រាវ និងមានទីកន្លែងសមរម្យ ស្ងប់ស្ងាត់សំរាប់ការសិក្សាស្រាវជ្រាវផងដែរ។

**ដើម្បីអភិវឌ្ឍន៍សមត្ថភាព ដើម្បីអនាគតភ្លឺស្វាងរបស់ខ្លួន សូមសិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវទូទៅ ចំណាយពេលវេលាអោយបានច្រើនជាអតិបរិមា ចូលអានសៀវភៅ-ឯកសារ ដែលមានប្រយោជន៍សំរាប់បង្កើនចំណេះដឹងរបស់ខ្លួន ជាពិសេសប្អូនៗនិស្សិត សូមកុំចំណាយពេលវេលាឥតប្រយោជន៍នៅក្នុងការដើរកំសាន្តគ្មានព្រំ-ដែន សេពគ្រឿងស្រវឹង គ្រឿងញៀន ប្រព្រឹត្តល្បែងស៊ីសង អំពើពាលាអាវ៉ាសែ ដែលសង្គមស្អប់ខ្ពើម និងមិនអោយតំលៃ។**

**ចំណេះ ជាទ្រព្យមិនអាចលួចប្លន់បាន ការក្រេបយកចំណេះវិជ្ជា មិនមានពេលបញ្ចប់ឡើយ ក្រេបច្រើន ចំរើនច្រើន។**

**ចំណេះនាំមកនូវភាពថ្លៃថ្នូរ!!!**

# ទំព័រឱកាសសំរាប់អ្នក

## Brief Job News

# ដំណឹងជ្រើសរើសបុគ្គលិក

| | |
|---|---|
| **UNDP** | : Monitoring and Evaluation Officer |
| **FIDR** | : Accountant |
| **WVC** | : Finance Officer |
| **FHI** | : Association Administrative Officer |
| **NLC/S** | : Administrative and Financial Assistant |
| **NGO Forum** | : Administration Officer |
| **ARD** | : Resource Person |

**The United Nation Development Programme** is seeking to fill as soon as possible the following vacancy in it office in Phnom Penh. Post Title: **Monitoring and Evaluation Officer**. The M& E Officer is responsible for internal monitoring and evaluation of UNDP programme in Cambodia through managing and leading the corporate monitoring and reporting processes; ensuring adherence to programme project monitoring plans; coordinating and consolidating input to substantive and thematic surveys; reviewing and advising on UN reform from a UNDP perspective and being the lead person for new corporate policies on programme/project design and implementation.

Detailed job descriptions of above post are on the website http://www.un.org.kh/undp/. Send your application letter, CV and the completed UN Personal History Form (P11) by email to applications.kh@undp.org, by identifying the post title in the subject line.

***Closing Date: April 2, 2007***

---

**Foundation for International Development/Relief**, a non-governmental humanitarian organization working for social development of Cambodia since 1992, announces a position vacancy for Cambodian nationals.

Position: **Accountant**
Project: Food and Nutrition Security Project (FNSP)
Base Location: Kampong Chhnang Province

**Responsibilities**

Prepare and control financial transactions/executions regarding the operations of FIDR Kampong Chhnang Project Office and its projects.
Assist project manager in managing project budget.
Producing monthly financial reports in English.
Maintain administration of FIDR Kampong Chhnang project office.

Interested candidates are encouraged to send a CV with cover letter and a recent photo to address below: #160, Street 71, Sangkat Tonle Basac, Khan Chamkarmon, Phnom Penh

***Closing Date: April 4, 20077***

**World Vision Cambodia (WVC)** is seeking for qualified Cambodian nationals to fill the position of **Finance Officer** for Takeo Operations based in Takeo Province. This position is primarily responsible for the overall coordination of the Program Office and Project accounting and financial reporting functions.

For job details and application please go to: http://www.worldvision.org.kh/news/joboppor.htm or contact our reception at *#20, St. 71, Sangkat Tonle Bassac, Khan Chamkarmon, Phnom Penh.*

***Closing Date: April 6, 2007.***

---

**Family Health International** is recruiting a Cambodian national to fill in the following position: **Associate Administrative Officer** – Phnom Penh (URGENTLY REQUIRED) (initial 5-month assignment, with possibility of extension). Please send CV and letter of application explaining your specific qualifications for the position to: sreytochn@fhi.org.kh or Ms. Nhim Sreytoch, FHI Office # 11 St. 302, Boe ung Keng Kang 1, Chamkar Mon, Phnom Penh.

***Closing Date: April 6, 2007***

---

**The National League of Commune/Sangkat (NLC/S)** under support of EC-UNDP, NLC/S is seeking one qualified Cambodian National to work day-to-day to fulfill **administrative and financial** tasks. The position is based in the Office of the NLC/S, Senate Campus, Phnom Penh.

Interested candidates are invited to send their letter of motivation and detail CV to: NLC/S Office, inside Campus of Senate, Chamcar Morn Monument, Tonle Bassac, Chamcar Mon, Phnom Penh. E-mail: nlc.s@online.com.kh or mary.sok@undp.org

***Closing Date: April 4, 2007***

---

**The NGO Forum** is seeking suitable Cambodian candidates for the position of **Administration Officer**, based in Phnom Penh.

Overall responsibility of the Administrative Officer is to ensure smooth coordination and provision of administrative activities to the whole NGO Forum Program based on three years action plan. The Administrative Officer reports directly to the Deputy Executive Director, under the general oversight of the Executive Director of the NGO Forum on Cambodia.

A detailed job description is available upon request from the NGO Forum Office, #9-11, St. 476, Phnom Penh. E-mail: lin@ngoforum.org.kh. Interested Candidates should send or email their CV and cover letter to the NGO Forum address.

***Closing Date: April 6, 2007***

ទំព័រឱកាសសំរាប់អ្នក

ដំណឹងជ្រើសរើសបុគ្គលិក

**Brief Job News Continue....**

# Resource Persons Requirement
# (Voluntary Service)

**Action for Research and Development (ARD) is a Cambodian Non-Governmental Organization** which had been running activity for almost one year, focused on Training, Newsletter Publication, Research, Community Development Project and Consultancy Service Provider.

*Currently, ARD are providing Consultancy Service (for Research and Training) and in the process of Building Confidential among NGOs/Institutions, Beneficiaries, and Donors by organizing and developing Training Courses for Young Graduates and NGO Staff, Newsletter Publication, Project Planning and Proposal Writing, Expanding the Training-Research Services.*

In order to run activity effectively according to the plan and reach our Objective *asap*, ARD are now ***seeking the Experience Resource Person Team (Voluntary Service)*** *to assist together with other Board Members, Founders and Voluntary Staff (who are currently playing the active and key roles) as ARD Family*.

**Responsibilities:** The Resource Persons will be responsible the following respective jobs:

1. ***Training and Research Team:*** Responsible for preparation and developing the Training Handout/Materials, Research Tools/Methodologies, and will play as Trainers during the Training Course conducted by ARD to Young Graduates/NGO Staff, and Consultancy Service Provider
2. ***Webpage Designing and Newsletter Publication Team:*** Responsible for designing the webpage and host the ARD information on website, search the information related to the ARD project activities, prepare and organize text for publishing ARD Monthly Newsletter.
3. ***Project Planning and Proposal Developing:*** Responsible for preparation and developing Strategic Plan, Project Proposal, and Building Good Communication and Relationship with other NGOs/Institutions.

**Main Note for Candidates:** The Resource Persons who were selected have to Carried Out their *Jobs as Part Time (at least available for working in the weekends)*. They will not get any salary and benefits in the period of None-Funding from donors, but they *will have a good opportunity to get automatic receiving salary and benefits according to performance (in case they interested) when ARD get services and fund support*. The post is under coordination and supervision of Executive Director and closed collaboration with ARD Founders and Voluntary Staff.

**Requirement:**

1. **Training and Research Team:** must be have background and experiences in preparation Training Handout/Materials, Research Tools/Methodologies, and used to Facilitate in the Training Courses.
2. **Webpage Designing and Newsletter Publication:** Must be IT background and have experiences in designing Webpage and Publish Newsletter.
3. **Project Planning and Proposal Developing:** Must be have background/experiences and well understanding in Project Planning, Proposal Writing.

**Interest *candidates who are willingness to contribute in building new NGO, wishing to become Consultancy Group and join as part of ARD Family Members*** *with our Board Members, Founders, and Voluntary Staff* (***both Foreigners and Cambodians***) are invited to submit **Cover Letter and CV with a current photo** by specifying the Team whish to apply not later than **13 April 2007** to the ARD office: #51F, Street 265, Teuk Laak III, Tuol Kuok, Phnom Penh, CCC Box: 304
**Tel. :** (855) 16 77 87 01/ (855) 12 478 874. **E-mail :** ard.cambodia@yahoo.com

# កសិកម្ម និងការអភិវឌ្ឍន៍

## ការយល់ដឹងបន្ថែមអំពី ប.វ.ស

ពតិមានសំខាន់សំរាប់អ្នក ធ្លាប់បានចុះផ្សាយម្តងរួចមកហើយកាលពីខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីអំពីបច្ចេកទេសប.វ.ស ហើយដោយយល់ឃើញថា ាមានសារៈសំខាន់ និងត្រូវបាន និងកំពុងយកចិត្តទុកដាក់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជាបណ្តាអង្គការមិនមែនរដ្ឋាភិបាល និងកសិករទូទៅ នៅលេខនេះ ពតិមានសំខាន់សំរាប់អ្នក សូមលើកយកបច្ចេកទេសប.វ.ស មកផ្សព្វផ្សាយបន្ថែម ដែលជាការបកស្រាយបំភ្លឺរបស់លោក បណ្ឌិតយ៉ង សាំងកុមារ ប្រធានអង្គការ CEDAC ដហើយដែលបានចុះនៅក្នុងទំព័រទស្សនាវដ្តីកសិករ មានដូចតទៅ :

១. ប.វ.ស មិនមែនចង់និយាយតែអំពីការស្ទូង ១ដើម នោះទេ។ ការស្ទូង ១ដើម គ្រាន់តែជាបច្ចេកទេស រឺគោលការណ៏ក្នុងចំណោមគោលការណ៏ជាច្រើនប៉ុណ្ណោះ ដូចជាការប្រើសំណាបអាយុខ្លី ការស្ទូងជាជួរបន្ទាត់ ការគ្រប់គ្រងទឹក...។ ដោយឡែកចំពោះកសិករ នៅមានការភ័យខ្លាចចំពោះការស្ទូង១ដើម។ យើងអាចធ្វើការស្ទូង ២ រឺ៣ដើម ក៏ប៉ុន្តែប្រសិនបើយើងមានសំណាបថ្លោសល្អ ការស្ទូង១ ដើម វាប្រសើរជាង ដោយសារស្រូវអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបែកគុម្ព។

២. កសិករខ្លះនិយាយថា ដោយសារមានភាពរាំងស្ងួត នាំអោយសំណាបចាស់ជ្រុល ដូចនេះគាត់មិនអាចធ្វើតាម ប.វ.ស បានទេ។ ខ្ញុំសូមបញ្ជាក់ថា ប្រសិនបើសំណាបចាស់ យើងនៅតែអាចអនុវត្តនូវបច្ចេកទេសមួយចំនួនរបស់ប.វ.ស បានដែរ ដូចជាយើងស្ទូង១ដើម រឺ២ដើម ស្ទូងអោយរាងញឹកជាងពេលស្ទូងសំណាបខ្ចី កុំអោយទឹកច្រើនពេលស្ទូង និងពេលស្រូវបែកគុម្ព ។ល។

៣. មានកសិករខ្លះនិយាយថា ស្រែរបស់គាត់មានទឹកច្រើន ហើយគាត់មិនអាចបង្ហូរចេញបានទៀត ដូចនេះគាត់មិនអាចអនុវត្តតាមប.វ.ស បានទេ។ តាមបទពិសោធន៏ យើងយល់ថាយើងនៅតែអាចធ្វើបានដូចជា ការស្ទូងសំណាបដែលមានអាយុចាស់បន្តិចដោយរើសតែសំណាបដែលថ្លោស ដើម្បីស្ទូង ស្ទូងរាងញឹកជាងបន្តិច ស្ទូងអោយមានជាជួរបន្ទាត់ ។ល។

៤. កសិករខ្លះនិយាយថា គាត់អត់មានជីធម្មជាតិគ្រប់គ្រាន់ ដូចនេះគាត់មិនអាចអនុវត្តតាមបច្ចេកទេសប.វ.ស បានទេ ត្រង់នេះ យើងខ្ញុំសូមបញ្ជាក់ថា ប្រសិនបើបងប្អូនមិនមានជីធម្មជាតិគ្រប់គ្រាន់ យើងក៏អាចអនុវត្តតាមបច្ចេកទេសមួយចំនួនទៀត ដូចជាការស្ទូងចាប់មួយដើម រឺ២ដើម ការស្ទូងជាជួរ ការដកស្មៅ ។ល។

**សរុបមក ប.វ.ស មិនមែនផ្តោតតែទៅលើបច្ចេកទេសអ្វីមួយនោះទេ គឺជាការផ្គុំចូលគ្នានូវបច្ចេកទេសជាច្រើន។** ប្រសិនបើកសិករមានភាពប៉ិនប្រសប់ អាចផ្គុំគ្រប់បច្ចេកទេសបានល្អ ពេលនោះយើងក៏ទទួលបានផលល្អដែរ វាមិនខុសពីការស្លកកូរ ប្រសិនបើយើងមានគ្រឿងគ្រប់ ហើយអ្នកស្លមានភាពចំណាប់ យើងក៏បានសម្លឆ្ងាញ់ដែរ តែបើយើងខ្វះគ្រឿង១មុខ រឺ២មុខ យើងក៏អាចបានសម្លដែរ គ្រាន់តែវាមិនសូវឆ្ងាញ់ដូចមានគ្រឿងគ្រប់មុខ។

**ដូចបងប្អូនជ្រាបស្រាប់ហើយ ថា ចំនួនប្រជាជនពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយឆ្នាំទៅមួយឆ្នាំ កើនឡើងជាលំដាប់ ដែលធ្វើអោយតំរូវការ ជាពិសេសស្បៀងអាហារ ត្រូវមានកំណើនឡើងដែរ ប៉ុន្តែទំហំដីធ្លីសំរាប់ប្រកបរបរធ្វើស្រែចំការ នៅដដែល មិនមានកើនឡើយ ហេតុនេះពតិមានសំខាន់សំរាប់អ្នក សូមធ្វើការអំពាវនាវដល់ប្រជាកសិករទូទាំងព្រះរាជាណាចក្រកម្ពុជា ផ្លាស់ប្តូរ នូវវិធីសាស្រ្តធ្វើស្រែចំការតាមទំលាប់បុរាណ (ដែលនៅពេលដំណាក់កាលនោះតំរូវការនៅតិចតួចនៅឡើយ) ហើយមកចាប់យកការអនុវត្ត តាមវិធីសាស្រ្តទំនើប ងាយស្រួលអនុវត្ត ចំណាយទុនតិច ដែលបច្ចេកទេសទាំងអស់នោះ បាននិងកំពុងផ្សព្វផ្សាយនៅតាមមូលដ្ឋាន របស់បងប្អូន ដោយភ្នាក់ងាររបស់អង្គការអភិវឌ្ឍន៏នានា ស្ថាប័នបច្ចេកទេសរបស់រាជរដ្ឋាភិបាល។**

**សូមកុំស្ទាក់ស្ទាក់ក្នុងការសួរនាំ ដើម្បីយល់ដឹងពីបច្ចេកទេសថ្មីៗល្អៗ។**

# កសិកម្ម និងការអភិវឌ្ឍន៍

## បទពិសោធន៍កំចាត់ក្ដាមកាត់ស្រូវដោយប្រើលាមកសេះ

នៅប្រទេសកម្ពុជា នាពេលបច្ចុប្បន្ននេះ បច្ចេកទេសកសិកម្ម និងធនធានសំរាប់ប្រើប្រាស់នៅក្នុងផលិតកម្ម នៅមិនទាន់ឆ្លើយតបបានទៅនឹងតំរូវការជាក់ស្ដែងឡើយ។ ហើយការធ្វើផលិតកម្មស្រូវ ជាញឹកញយ និងទំលាប់ គឺត្រូវពឹងផ្អែកទៅលើធម្មជាតិ (ភ្លៀង) ទាំងស្រុង ដោយមិនទាន់មានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់ ជាពិសេសជាងនេះទៀតស្រូវរបស់ប្រជាកសិករយើង តែងតែត្រូវបានរំខាន និងបំផ្លាញដោយកត្តាចង្រៃផ្សេងៗ មានដូចជា ជំងឺ សត្វបំផ្លាញ ជាដើម។ ដើម្បីចូលរួមចំណែកនៅក្នុងការកាត់បន្ថយបញ្ហាដែលបានកើតឡើងចំពោះប្រជាកសិករ ពតិមានសំខាន់សំរាប់អ្នកនៅលេខនេះ សូមលើកយកពីបទពិសោធន៍ក្នុងការកំចាត់ក្ដាមកាត់ស្រូវ ដែលបានចុះនៅក្នុងទំព័រទស្សវដ្ដីកសិករ របស់អង្គការ CEDAC ដូចតទៅ:

ក្ដាម ជាសត្វមួយប្រភេទដែលកសិករតែងតែជួបប្រទះឃើញវាមកកាត់បំផ្លាញលើដំណាំស្រូវ ដែលស្ទូងហើយភ្លាមៗ រឺក្នុងអំឡុងពេលមួយសប្ដាហ៍ក្រោយពេលស្ទូងរួច។ បញ្ហានេះ ធ្វើអោយកសិករមួយចំនួនបង្ខំចិត្តទៅទិញថ្នាំក្ដាមមកកម្ចាត់។

ប៉ុន្តែដោយឡែក កសិករឈ្មោះ យ៉ុម យ៉ុង អាយុ ៤៣ឆ្នាំ រស់នៅភូមិពោធិស្មោង ឃុំសណ្ដែក ស្រុកបាធាយ ខេត្តកំពង់ចាម បានប្រើប្រាស់វិធីសាស្ត្រសាមញ្ញក្នុងការកម្ចាត់ក្ដាមដោយប្រើប្រាស់លាមកសេះ ដែលគាត់ចេះបទពិសោធន៍នេះពីបុរសម្នាក់មកពីស្រុកចំការលើ ខេត្តកំពង់ចាម ដែលបានដើរលក់ចេកនៅក្នុងភូមិរបស់គាត់។ ពេលមកដល់ផ្ទះរបស់គាត់ ស្រាប់តែកសិករលក់ចេកនោះ និយាយថា "ផ្ទះនេះមានសេះ ហើយបែរជាអោយក្ដាមមកកាត់ស្រូវបានទៀត"។ ពេលបានឮដូច្នេះ គាត់ក៏ជជីកសួរពីវិធីសាស្ត្រកម្ចាត់ក្ដាម។ *<u>ក្រោយពេលកសិករលក់ចេកប្រាប់រួច គាត់ក៏បានយកលាមកសេះ មកបាចសាកល្បងនៅលើស្រែរបស់គាត់ដែលមានសត្វក្ដាមកំពុងបំផ្លាញលុះព្រឹកឡើង គាត់សំគាល់ឃើញថា មិនមានសត្វក្ដាមនៅក្នុងស្រែរបស់គាត់ទៀតទេ</u>*។ គាត់មានការជឿជាក់ជាខ្លាំង ហើយសព្វថ្ងៃនេះ គាត់មិនដែលទិញថ្នាំក្ដាមមកប្រើប្រាស់លើស្រែរបស់គាត់ទេ គាត់ប្រើតែលាមកសេះនៅលើផ្ទៃដីប្រហែល ២ហិកតា បច្ចុប្បន្ននេះ មានកសិករជាច្រើននៅក្នុងភូមិ និងក្រៅភូមិ ដែលនៅក្បែរៗនោះ បានអនុវត្តវិធីកម្ចាត់ក្ដាមរបស់លោកពូ។

**របៀបប្រើ :**

- យកលាមកសេះស្រស់ រឺក្រៀម (ស្រស់ល្អជាងក្រៀម) ១ល្អី (១០គីឡូក្រាម) អាចប្រើលើផ្ទៃដី ១០អារ
- បាចនៅចំកណ្ដាលស្រែ រឺពីលើខ្យល់ក៏បាន
- បាចនៅពេលមានក្ដាមកាត់ រឺពេលស្ទូងហើយក៏បាន (បើស្ទូងភ្លាម គួរបាចលាមកសេះក្រៀមភ្លាមៗ)
- ក្រោយពេលបាចរយៈពេល ១-៣ថ្ងៃ ក្ដាមចាប់ផ្ដើមបាត់អស់ពីស្រែ ពេលខ្លះបើគាត់ឃើញនៅលើភ្លឺស្រែមានរន្ធក្ដាមច្រើន គាត់ក៏យកលាមកសេះ មករោយនៅក្បែរៗរន្ធក្ដាមនោះរយៈពេលមួយយប់ ក្ដាមចេញអស់ពីរន្ធ និងលើភ្លឺ។

តាមការពិសោធន៍របស់គាត់ ឃើញថា ដោយសារលាមកសេះមានក្លិនអាក្រក់ ឆ្អេះខ្លាំងផង វាមិនអាចសម្លាប់ក្ដាមក៏ពិតមែន តែវាអាចបណ្ដេញក្ដាមអោយទៅឆ្ងាយបាន។

**យោងតាមបទពិសោធន៍ខាងលើនេះ ប្រសិនបើប្រជាកសិករមានជួបប្រទះបញ្ហាក្ដាមកាត់ស្រូវ សូមបងប្អូនព្យាយាមសាកល្បងប្រើប្រាស់នូវលាមកសេះ ដើម្បីកម្ចាត់ក្ដាមចេញពីស្រែ ពីព្រោះវាជាវិធីសាមញ្ញ និងមិនត្រូវចំណាយថវិកាទៀតផង។**

**ពតិមានសំខាន់សំរាប់អ្នក រីករាយនឹងពាំនាំនូវវិធីសាស្ត្រសាមញ្ញ ងាយៗ និងមិនចំណាយថវិកា ដើម្បីជំរាបដល់ប្រជាកសិករបន្ថែមទៀតនៅលេខក្រោយ។**

# ទំព័រធនធានធម្មជាតិ និងបរិស្ថាន

## ប្រទេសកម្ពុជា បាន និង កំពុងទទួលរងនូវការគំរាមកំហែងដោយសារទំនប់ជាច្រើននៅក្នុងប្រទេសឡាវ

តាមការចុះនៅក្នុងព្រឹត្តបត្តធម្មជាតិ និងជីវិត របស់សមាគមថែរក្សាបរិស្ថាន និងវប្បធមិ នាខែកញ្ញា-តុលា ឆ្នាំ២០០៦ បានដកស្រង់អត្ថបទរបស់លោក Anurak Wangpattan បានសរសេរថា ទំនប់ធំៗចំនួន៩ នឹងត្រូវគេសាងសង់នៅក្នុងទន្លេសេកុង និងនៅតាមដៃទន្លេសំខាន់ៗ ហើយមានទំនប់ជាច្រើនទៀតអាចនឹងត្រូវសាងសង់នៅតាមដៃទន្លេតូចៗនៃទន្លេសេកុងនេះផងដែរ។ គំរោងរបស់រដ្ឋាភិបាលនៃប្រទេសឡាវក្នុងការសាងសង់ទំនប់នេះឡើង គឺដើម្បីផលិតថាមពលអគ្គិសនីលក់អោយប្រទេសវៀតណាម។

រាល់ការសាងសង់ទំនប់នីមួយៗនៅក្នុងអាងទន្លេសេកុង នៃប្រទេសឡាវ ផលប៉ះពាល់មកលើប្រទេសកម្ពុជានឹងបន្តកើនឡើងដូចបទពិសោធន៏ពីទន្លេសេសានបង្ហាញអោយឃើញពីប្រភេទ និងទំហំនៃការខូចខាតពីផលប៉ះពាល់ដែលនឹងអាចកើតមានឡើងនៅទន្លេសេកុង និងសហគមន៏តាមបណ្តោយទន្លេនេះផងដែរ។

ប្រជាជននៅតាមបណ្តោយទន្លេសេកុង បានរាយការណ៏អោយដឹងថា ការនេសាទ ជាមុខរបរសំខាន់របស់ពួកគាត់ នៅក្នុងរដូវប្រាំង រីឯកន្លែងនេសាទសំខាន់ៗគឺស្ថិតនៅក្នុងបរិវេនទឹកជ្ជូរ និងនៅតាមអន្លង់ជ្រៅៗ។ ពិតណាស់ការបំផ្លាញទឹកជ្ជូរ និងអន្លង់ជ្រៅៗ នឹងផ្តល់នូវផលប៉ះពាល់ដែលមិនអាចជៀសវាងបាន និងមានរយៈពេលយូរ ទៅលើធនធានមច្ឆានៅក្នុងទន្លេសេកុង និងទៅលើសន្តិសុខស្បៀងរបស់ប្រជាជនដែលរស់នៅតំបន់នេះ។ ការរស់នៅ និងការចិញ្ចឹមជីវិតរបស់ប្រជាជនប្រមាណ៣០ ០០០នាក់នៅក្នុងខេត្តស្ទឹងត្រែងនៃប្រទេសកម្ពុជា នឹងទទួលរងការគំរាមកំហែងពីគម្រោងសាងសង់ទំនប់វារីអគ្គិសនីជាច្រើននៅប្រទេសឡាវនេះ ហើយវាក៏អាចរីករាលដាលប៉ះពាល់ផងដែរទៅដល់ទន្លេសេសាន និងទន្លេស្រែពកដែលជាដៃទន្លេដ៏សំខាន់របស់ទន្លេសេកុង ហើយទន្លេនេះហូរចាក់ចូលទៅក្នុងទន្លេងមេគង្គ ដូចគ្នានេះដែរវានឹងធ្វើអោយប៉ះពាល់ដល់បឹងទន្លេសាបទៀតផង។

លោកទេព ប៊ុណ្ណារិទ្ធិ នាយកប្រតិបត្តិសមាគមថែរក្សាបរិស្ថាន និងវប្បធមិ បានមានប្រសាសន៏ថា "វាប្រាកដណាស់ថានឹងមានផលប៉ះពាល់យ៉ាងខ្លាំង ទៅលើបរិស្ថានគុណភាព និងបរិមាណទឹក ប្រព័ន្ធជីវៈចំរុះ និងតុល្យភាពបរិស្ថាននៃទន្លេសេកុងនៅក្នុងប្រទេសកម្ពុជា ប្រសិនបើទំនប់ទាំងនោះ ត្រូវបានគេសាងសង់ឡើងក្នុងអាងទន្លេសេកុង ដែលស្ថិតនៅក្នុងប្រទេសឡាវ។ តាំងពីគម្រោងសាងសង់ទំនប់បានស្នើ រដ្ឋាភិបាលឡាវមិនមានវិធានការដើម្បីបញ្ចៀស រឺកាត់បន្ថយនូវផលប៉ះពាល់ទាំងនោះទេ តែបែរជាបន្តការយល់ព្រម និងចូលរួមយ៉ាងសកម្មនៅក្នុងគំរោងសាងសង់ទំនប់ទាំងនោះទៅវិញ"។ លោកបានបន្តថា "ដូចធ្លាប់មានបទពិសោធន៏នៅទន្លេសេសាន និងនៅអាងទន្លេមេគង្គរួចហើយ នៅពេលដែលទំនប់ជាច្រើនត្រូវបានយល់ព្រមអោយសាងសង់ហើយ ផលប៉ះពាល់ជាច្រើនកើតឡើងនោះ រដ្ឋាភិបាល និងអ្នកវិនិយោគទុនទាំងនោះមិនសូវមានការចាប់អារម្មណ៏ និងឈឺឆ្អាលក្នុងការជួយសម្រាលនូវផលប៉ះពាល់ទាំងនោះឡើយ"។

លោកទេព ប៊ុណ្ណារិទ្ធិ បានបន្តថា រដ្ឋាភិបាលកម្ពុជា មានការពឹងផ្អែកលើគណៈកម្មការទន្លេមេគង្គ ដើម្បីសម្តែងពីការព្រួយបារម្ភអំពីផលប៉ះពាល់ដែលកើតមានឡើងពីការសាងសង់ទំនប់វារីអគ្គិសនីនេះ ទៅកាន់ប្រទេសឡាវ។ ហើយយ៉ាងហោចណាស់ ប្រទេសកម្ពុជាគួរតែទាមទារអោយមានការវាយតំលៃហេតុផលប៉ះពាល់សង្គម និងបរិស្ថានផ្សេងៗដោយឯករាជ្យមួយ មុននឹងចាប់ផ្តើមធ្វើការសាងសង់ទំនប់ក្នុងអាងទន្លេសេងកុង ទន្លេមេគង្គ ទន្លេសេសាន និងទន្លេស្រែពក។ សហគមន៏មូលដ្ឋាន ដែលរស់នៅតាមបណ្តោយទន្លេសេកុង ក្នុងខេត្តស្ទឹងត្រែង គួរតែត្រូវបានជូនដំណឹងអំពីផលប៉ះពាល់ទាំងនោះ និងទទួលបាននូវឱកាសបន្ថែមទៀតក្នុងការបង្ហាញនូវការព្រួយបារម្ភរបស់ពួកគាត់ ទៅកាន់រដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលឡាវផងដែរ។

# ជីវិត និងសង្គម

## របាយការណ៍៖ អនាគតយុវជនកម្ពុជាមិនទាន់មានភាពច្បាស់លាស់

របាយការណ៍សំរាប់ការអភិវឌ្ឍន៍ពិភពលោកប្រចាំឆ្នាំ២០០៧របស់ធនាគារពិភពលោក ដែលមានចំណងជើងថា ”ការអភិវឌ្ឍន៍ និងមនុស្សជំនាន់ក្រោយ ” ដែលបានចេញនាពាក់កណ្តាលខែមីនានេះ បានលាបពណ៌ដ៏ស្រអាប់ពីលទ្ធភាព នៃការសិក្សា និងឱកាសស្វែងរកការងាររបស់យុវជនកម្ពុជា។

លោកស្រី នីហ្សា អាក្រាវ៉ាល់ អ្នកគ្រប់គ្រងប្រចាំប្រទេសនៃធនាគារពិភពលោក បានមានប្រសាសន៍កាលពីពេលបញ្ចេញរបាយការណ៍នេះ នៅក្នុងទីក្រុងភ្នំពេញថា ” កុមារនៅក្នុងប្រទេសកម្ពុជាប្រឈមមុខនឹងអនាគតមិនច្បាស់លាស់មួយ ”។ លោកស្រី បានមានប្រសាសន៍ថា សូម្បីតែនិស្សិតដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ ក៏មិនត្រូវបានគេធានាសំរាប់ការស្វែងរកការងារដែរ ព្រោះការងារជាច្រើនកំពុងមានការខ្វះខាត ហើយគុណភាពផ្នែកឧត្តមសិក្សាក៏មិនទាន់មានភាពច្បាស់លាស់ទៀត ”។

លោកស្រី អាក្រាវ៉ាល់ បានមានប្រសាសន៍បន្តទៀតថា ៧០ភាគរយនៃប្រជាពលរដ្ឋ គឺស្ថិតក្រោមអាយុ៣០ឆ្នាំ ហើយថ្វីបើការចុះឈ្មោះចូលរៀននៅបឋមសិក្សាបានកើនឡើង ហើយឥឡូវនេះបានកើនលើសពី៩០ភាគរយក៏ដោយ ក៏ស្ទើរតែពាក់កណ្តាលនៃចំនួនសិស្សនៅបឋមសិក្សារបស់ប្រទេសនេះ បានបោះបង់សាលាមុនពេលពួកគេបញ្ចប់ការសិក្សា។

លោកស្រីអាក្រាវ៉ាល់ បានមានប្រសាសន៍ថា ការចុះឈ្មោះចូលរៀនមានតែ៣០ភាគរយប៉ុណ្ណោះនៅអនុវិទ្យាល័យ ហើយវាបានធ្លាក់ដល់១១ភាគរយនៅថ្នាក់វិទ្យាល័យ។ លោកស្រីបានមានប្រសាសន៍ថា ធនាគារពិភពលោកបានផ្តល់ប្រាក់ចំនួន ២៨លានដុល្លារ ដល់ក្រសួងអប់រំ ដើម្បីពង្រីកលទ្ធភាព នៃការអប់រំជាមូលដ្ឋានជាពិសេសសំរាប់សិស្សស្រី-សិស្សក្រីក្រ។

សូម្បីតែសិស្សដែលបានរៀនចប់ ក៏មានការលំបាកក្នុងការរកធ្វើអោយការសិក្សារបស់ពួកគេផ្តល់ផលមកវិញនៅក្នុងទីផ្សារពលកម្មដែរ។

**យោងទៅតាមលោក ជាវ យូម៉េង ប្រធានសមាគមយុវជនខ្មែរ បានអោយដឹងថា ចំនួននិស្សិតដែលបានបញ្ចប់ការសិក្សា នៅតាមសាកលវិទ្យាល័យនានាក្នុងប្រទេសកម្ពុជាមានចំនួនពី ៤០ ០០០ ទៅ ៥០ ០០០នាក់ ក្នុងមួយឆ្នាំៗ ហើយមានតែម្នាក់ប៉ុណ្ណោះ ក្នុងចំណោម៩នាក់ដែលមានការងារធ្វើ។** លោកបានមានប្រសាសន៍ថា ”ភាពគ្មានការងារធ្វើរបស់យុវជន គឺជក្តីបារម្ភធំបំផុត ” ដោយលោកបន្ថែមថា វាបាននាំទៅរកក្តីអស់សង្ឃឹម និងបញ្ហាសង្គមជាច្រើន។

នៅក្នុងរបាយការណ៍របស់ខ្លួន ធនាគារពិភពលោកក៏បានសង្កត់ធ្ងន់ផងដែរទៅលើគ្រោះថ្នាក់ទាំងឡាយ ដែលយុវជនគ្មានការងារធ្វើ ប្រហែលជាអាចជះឥទ្ធិពលសំរាប់សង្គម។ ធនាគារពិភពលោកបានអោយដឹងថា ប្រសិនបើយុវជននៅតែគ្មានការងារធ្វើក្នុងរយៈពេលដ៏យូរខាងមុខដូចដែលបានកើតឡើងនៅពេលក្មេងៗបានកើនច្រើននៅអឺរ៉ុប និងសហរដ្ឋអាមេរិក (បន្ទាប់ពីសង្គ្រាមលោកលើកទី២) នោះ វាមិនមែនគ្រាន់តែជាការបោះបង់ចោលធនធានមនុស្សប៉ុណ្ណោះទេ វាថែមទាំងជាការប្រថុយប្រថានក្នុងការរំពឹងទុកមិនត្រឹមត្រូវ និងចលាចលក្នុងសង្គមដែលអាចធ្វើអោយប៉ះពាល់បរិយាកាសវិនិយោគទុន និងកំណើនវិនិយោគ។

**លោកកុល ផេង រដ្ឋមន្ត្រីក្រសួងអប់រំ បានអំពាវនាវដល់សាកលវិទ្យាល័យទាំងអស់ អោយរឹតបន្តឹងចំណងទាក់ទងរបស់ពួកគេ ជាមួយនឹងទីផ្សារការងារតាមរយៈកម្មវិធីស្ម័គ្រចិត្ត និងកម្មវិធីហាត់ការ។ លោកក៏បានជំរុញដល់និស្សិតសាកលវិទ្យាល័យផងដែរ សូមកុំសូវផ្តោតទៅលើការមានសញ្ញាប័ត្រច្រើន ហើយគួរតែផ្តោតអារម្មណ៍ជាខ្លាំង ទៅលើបទពិសោធន៍ជាក់ស្តែងរបស់ពួកគេ។ និស្សិតមិនគួររត់ទៅរៀនសាលាពេទ្យផង ហើយនៅពេលជាមួយគ្នានេះ ទៅរៀនសាលាច្បាប់ផងទេ។ រៀនតែមួយមុខ ហើយវានឹងមានភាពច្បាស់លាស់ទៅលើអ្វីដែលអ្នកបានរៀន។**

# ជីវិត និងសង្គម

## ម្តាយគ្រូបង្រៀនដែលជាប់ពន្ធនាគារសុំទោសចំពោះនាយករដ្ឋមន្ត្រី

ចាប់តាំងពីខែវិច្ឆិកាឆ្នាំ២០០៦ កន្លងមក ដែលសាស្ត្រាចារ្យមួយរូបបង្រៀននៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ្យ ត្រូវបានតុលាការចោទប្រកាន់ និងឃុំខ្លួននៅពន្ធនាការព្រៃសរនោះមក បានធ្វើអោយបណ្តាអង្គការសង្គមស៊ីវិលជាច្រើនធ្វើការតាមដានជាប់ជាប្រចាំអំពីករណីលើកដំបូងបំផុត ដែលមានសាស្ត្រាចារ្យហ៊ានបង្រៀនសិស្ស និស្សិតនៅក្នុងថ្នាក់ដោយរិះគន់រដ្ឋាភិបាល ជាពិសេសចំពោះលោកនាយករដ្ឋមន្ត្រីហ៊ុន សែន។

តាមការចុះផ្សាយពត៌មានរបស់ព្រឹត្តិបត្រ Cambodia Daily នាថ្ងៃទី៩ ខែមីនា ឆ្នាំ២០០៧ បានអោយដឹងថា កាលពីដើមខែមីនាកន្លងទៅនេះ ម្តាយរបស់លោកទៀង ណារិទ្ធ ដែលជាសាស្ត្រាចារ្យជាប់ពន្ធនាគារម្នាក់ដែលត្រូវបានកាត់ទោសកាលពីសប្តាហ៍មុនអោយជាប់ពន្ធនាគារ២ឆ្នាំកន្លះពីបទបង្រៀនតាមសៀវភៅដែលចងក្រងខ្លួនឯង ប្រឆាំងរដ្ឋាភិបាលនោះ បានសុំទោសលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន តាងនាមអោយកូនប្រុសរបស់អ្នកស្រី ហើយបានអំពាវនាវអោយដោះលែងកូនប្រុសរបស់គាត់។

លោកទៀង ណារិទ្ធ ដែលគេជឿថាទទួលរងបញ្ហាផ្លូវចិត្តនោះ ត្រូវបានឃុំនៅពន្ធនាគារព្រៃស ចាប់តាំងពីខែវិច្ឆិកាពីបទបង្រៀនតាមសៀវភៅដែលបោះពុម្ពដោយខ្លួនឯង ដែលភ្ជាប់ក្រុមមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ទៅនឹងសកម្មភាពហឹង្សាខាងនយោបាយ។

តាមព្រឹត្តិបត្តិ Cambodia Daily ដដែល បានអោយដឹងថា អ្នកស្រីគង់ សុផុន អាយុ៥៩ឆ្នាំ បាននិយាននៅក្នុងបទសម្ភាសកាលពីថ្ងៃព្រហស្បតិ៍ថា " ខ្ញុំ សុំទោសសម្តេចហ៊ុន សែន ដែលកូនប្រុសរបស់ខ្ញុំបានប្រើពាក្យមិនសមរម្យ "។ អ្នកស្រីបានបន្ថែមថា "កូនប្រុសរបស់ខ្ញុំ មានការលំបាកខាងផ្លូវចិត្ត។ ចាប់តាំងពីកូនខ្ញុំបានជាប់ពន្ធនាគារមក ខ្ញុំគិតតែយំ "។

ម្តាយរបស់លោក ទៀង ណារិទ្ធ បាននិយាយថា លោកទៀង ណារិទ្ធ មានអាយុ៣១ឆ្នាំ កំពុងត្រូវឃុំឃាំងនៅក្នុងបន្ទប់ទំហំ ៤ម៉ែត្រ គុណនឹង ៤ម៉ែត្រ ជាមួយអ្នកទោស១៦នាក់ផ្សេងទៀត។

លោកជិន លីដា អ្នកគ្រប់គ្រងកម្មវិធីពន្ធនាគារនៅអង្គការសិទ្ធិមនុស្សក្នុងស្រុកលីកាដូ បានមានប្រសាសន៍ថា កាលពីថ្ងៃទី១ ខែមីនា លោក និងវេជ្ជបណ្ឌិតអង្គការលីកាដូម្នាក់ បានទៅសួរសុខទុក្ខលោកទៀង ណារិទ្ធ ដែលបានប្រាប់គាត់ថា គាត់ទទួលរងការរមាស់ ហើយបានត្អូញត្អែរថា ឈឺក្បាល។

សុខភាពផ្លូវចិត្តរបស់លោក ទៀង ណារិទ្ធ ត្រូវបានវាយតំលៃមុនការកាត់ទោសគាត់ កាលពីថ្ងៃទី ២៨ខែកុម្ភៈ ប៉ុន្តែគ្រួសាររបស់គាត់ មេធាវី និងចៅក្រមដែលបានសំរេចករណីរបស់គាត់ អ្នកទាំងអស់គ្នានិយាយថា ពួកគេមិនបានឃើញលទ្ធផលទេ

លោក ម៉ុង គឹមហេង ប្រធានពន្ធនាគារព្រៃស បានមានប្រសាសន៍ថា ពន្ធនាគារមិនមានជំងឺផ្លូវចិត្ត និងមិនមានការរមាស់ទេ។ លោកក៏បានមានប្រសាសន៍ផងដែរថា អ្នកទោសរូបនេះស្ថិតនៅក្នុងបន្ទប់មួយជាមួយអ្នកទោស១២នាក់ ហើយថាការផ្លាស់ប្តូរទៅបន្ទប់ដែលមានមនុស្សតិចជាងនេះ មិនមែនជាជំរើសនោះទេ ព្រោះលោកបន្ថែមថា បន្ទប់ទាំងអស់ គឺដូចតែគ្នាហ្នឹង។

***ពត៌មានសំខាន់សំរាប់អ្នក កត់សំគាល់ឃើញថា ជារឿងធម្មតាក្នុងករណីដែលមានការរិះគន់ រឺបរិហាររដ្ឋាភិបាល រឺមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល ជានិច្ចកាលសំណុំរឿងនោះ ត្រូវបានចាត់ការយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធិភាពទៀតផង ទោះបីជាការកាត់ទោសរបស់តុលាការ ហាក់មានភាពលំអៀង ក្នុងករណីខ្លះក៏ដោយចុះ ប៉ុន្តែប្រសិនបើសំណុំរឿង ដែលពាក់ព័ន្ធនឹងឃាតកម្មទៅលើសកម្មជន ដែលមាននិន្នាការប្រឆាំងរដ្ឋាភិបាលវិញ រឺឃាតកម្មលើសិល្បៈករ សិល្បការនី កន្លងមក ចាប់តាំងពីឆ្នាំ២០០៧ និងបន្តហូរហែរមក មិនដែលឃើញសមត្ថកិច្ច រឺតុលាការ ចាត់វិធានការបានសំរេចឡើយ ដែលករណីនេះធ្វើអោយទាំងមតិជាតិ-អន្តរជាតិដាក់ជាសញ្ញាសួរថា ហេតុអ្វី???***



# ទំព័រចុងក្រោយសំរាប់អ្នក

**សូមបោះឆ្នោតជូនប្រាសាទអង្គរវត្ត ជាអច្ឆរិយទាំង៧ក្នុងពិភពលោក**

| |
|---|
| **LE CRI D’APPEL DE « ANGKOR WAT »** |
| **សំរែកប្រាសាទអង្គរវត្ត** |
| **THE CRY OF CALL OF « ANGKOR WAT »** |

**<< EMMENEZ-MOI AU « 7 MERVEILLES DU MONDE »;
VOUS SEREZ TRES NOBLEMENT HONORE >>**

**<<សូមមេត្តាជួយនាំអោយខ្ញុំបានដល់ ”អច្ឆរិយវិមានពិភពលោកទាំង៧ ”**

**លោកអ្នកនាង នឹងមានមហាកិត្តិយសដ៏ឧត្តុង្គឧត្តម >>**

**<< TAKE ME ALONG TO THE « 7 WONDERS OF THE WORLD »;**

***YOU WILL VERY NOBLEMENT BE HONOURED >>***

******

**- Ensemble, aidons-le ; soutenons-le ; emmenons-le jusqu’au
« 7 Merveilles du Monde » et donc, mobilisons-nous, s’il vous plait, merci.**

**~ ទាំងអស់គ្នា ខំជួយ ខំគាំទ្រ ខំនាំប្រាសាទយើង អោយបានដល់**

**”អច្ឆរិយវិមានពិភពលោកទាំង៧ ”ៗ ដូច្នេះយើងត្រូវកេណ្ឌកម្លាំងគ្នា, សូមអរគុណៗ**

**- Together, let us help it, let us support it, it along until the « 7 wonders
of the world », and we mobilize take, please, thank you.**

**Vote: www.new7wonders.com**

**Comité de Soutien « ANGKOR Wat » à l’élection des « 7 Merveilles du Monde »**

**E.mail : haing-kheang.lim@wanadoo.fr**